**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៣៣៤៥ ស.ស.ន

# សេចក្ដីសម្រេច
## ស្ដីពី
## ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ
## ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនៅរាជធានី ខេត្ត

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ០៦៩ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងទេសចរណ៍ ស្ដីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.–**

រដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវទទួលខុសត្រូវអនុវត្តមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ដែលបានផ្ទេរប្រតិភូកម្មពីក្រសួងទេសចរណ៍តាមប្រកាសលេខ០៦៩ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងទេសចរណ៍។

**ប្រការ២.–**

រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងមុខងារដែលបានផ្ទេរប្រតិភូកម្មនេះ តាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត និងត្រូវរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវច្បាស់លាស់នៅក្នុងទីចាត់ការអន្តរវិស័យ ដើម្បីធានាដល់ការគ្រប់គ្រង ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារនេះ។

ការអនុវត្តមុខងារស្តីពី "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ត្រូវអនុលោមបែបបទ លក្ខខណ្ឌ និងនីតិវិធីដែលកំណត់ដោយក្រសួងទេសចរណ៍។

**ប្រការ៣.–**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានកសុការ និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ០៧ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងទេសចរណ៍*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ដូចប្រការ៣*
- *ឯកសារ កាលប្បវត្តិ*